កូនសោកស្ដាយណាស់ (Act of Contrition)

គ្រ. ព្រះជាម្ចាស់ជាព្រះបិតារបស់កូនអើយ!
កូនសោកស្ដាយណាស់ដោយបានប្រព្រឹត្តអំពើបាប
ដែលមិនគាប់ព្រះហឫទ័យព្រះអង្គ ។
សូមព្រះអង្គទ្រង់មេត្តាលើកលែងទោសឲ្យកូនរួចពីបាបផង
សូមប្រទានកម្លាំងឲ្យកូនជៀសវាងអំពើបាបតរៀងទៅ ។ អាម៉ែន ។

## ៣ - ពិធីលើកលែងទោស (Absolution)

នៅពេលនោះ លោកបូជាចារ្យទ្រាប់ដៃប្រទានលើកលែកទោសពីព្រះអម្ចាស់ ។ លោកបូជាចារ្យមានប្រសាសន៍ថា៖

ប. សូមព្រះបិតាជាអម្ចាស់ បង្ហាញធម៌មេត្តាករុណាឲ្យអ្នកស្គាល់ ។
ដោយព្រះយេស៊ូជាព្រះបុត្រា បានសោយទិវង្គត
និងមានព្រះជន្មរស់ឡើងវិញ
ព្រះបិតាបានសម្រោះសម្រួលមនុស្សលោកជាមួយព្រះអង្គ
ទ្រង់ក៏បានចាត់ព្រះវិញ្ញាណដ៏វិសុទ្ធមក ដើម្បីរំដោះបាបឲ្យយើង ។
សូមទ្រង់ព្រះមេត្តាលើកលែងទោសឲ្យអ្នក តាមរយៈព្រះសហគមន៍ ។
រីឯខ្ញុំវិញ ខ្ញុំសូមលើកលែងទោសអ្នក ដោយព្រះនាម ព្រះបិតា ✠ និង
ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

គ. អាម៉ែន

ប. សូមអញ្ជើញឲ្យបានសុខសាន្ត ។

គ. សូមអរព្រះគុណព្រះជាម្ចាស់ ។



# អគ្គសញ្ញាលើកលែងទោស

ធ្វើពិធីអគ្គសញ្ញាលើកលែងទោសជាមួយព្រះអង្គ លោកបូជាចារ្យជម្រាបអ្នកទទួលសារភាពថា៖

ប. ✠ **ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។**

គ្រ. អាម៉ែន ។

## ១ - ពិធីលន់តួ

អ្នកជំងឺមកជម្រាបលោកថា៖

គ្រ. សូមលោកជូនពរមកខ្ញុំ ព្រោះខ្ញុំជាអ្នកបាប ។

លោកបូជាចារ្យមានប្រសាសន៍ថា៖

ប. សូមព្រះជាម្ចាស់បំភ្លឺអ្នកឲ្យបានស្គាល់នូវអំពើបាបរបស់អ្នក
និងជំរុញអ្នកឲ្យបានផ្ញើខ្លួនទាំងស្រុង ទៅលើធម៌មេត្តាករុណា
ដ៏លើសលប់របស់ព្រះជាម្ចាស់ ។

រូបអ្នកជំងឺរៀបរាប់អំពើបាបដែលខ្លួនបានប្រព្រឹត្ត ។

លោកបូជាចារ្យក៏ជួយយោបល់ខ្លះៗ ដើម្បីឲ្យដើរតាមព្រះគ្រីស្ត និងរស់នៅយ៉ាងសមរម្យក្នុងឋានៈជាគ្រីស្តបរិស័ទ ។

លោកបូជាចារ្យសុំឲ្យអ្នកទទួលសារភាពសូត្រធម៌មួយ ឬថ្វាយដង្វាយអ្វីមួយ ឬធ្វើសកម្មភាពណាមួយតាមកាលៈទេសៈ ដើម្បីបង្ហាញថា អ្នកពិតជាចង់រួមរស់ជាមួយព្រះគ្រីស្ត ដែលបានបូជាព្រះជន្មនៅលើឈើឆ្កាងដើម្បីសង្គ្រោះយើង ។

## ២ - ពិធីសម្ដែងការនឹកស្ដាយរបស់ខ្លួន

គ្រីស្តបរិស័ទទទួលអគ្គសញ្ញាលើកលែងទោស អាចសូត្រធម៌៖